# តើដើមឈើអាចក្លាយជាថ្មបានយ៉ាងដូចម្ដេច?

បាតុភូតិធម្មជាតិជាច្រើនតែងមានការបកស្រាយប្លែកៗទៅតាមទម្លាប់ ជំនឿ និងការឃើញជាក់ស្ដែងរបស់ប្រជាជនតាមតំបន់ដែលពួកគេបានរស់នៅ។ តែក្រោយមកការបកស្រាយអំពីបាតុភូតិធម្មជាតិ គឺគេធ្វើតាមបែបវិទ្យាសាស្ត្រ ដោយគេផ្ដោតលើការសិក្សាស្រាវជ្រាវ និងវិភាគយ៉ាងស៊ីជម្រៅ ទើបគេអាចសន្និដ្ឋានថាជាបាតុភូតិធម្មជាតិជាអ្វីមួយ។ នៅក្នុងប្រទេសកម្ពុជា ប្រជាជនមួយចំនួនដែលធ្លាប់រស់នៅខេត្តស្ទឹងត្រែង និងខេត្តក្រចេះ ពួកគាត់ធ្លាប់ ឬពាក្យថា គគីរថ្ម។ គគីរថ្មជាអ្វី? គគីរថ្មជាឈ្មោះនៃប្រភេទដើមគគីរម៉្យាង និងមួយទៀតជាការហៅឈ្មោះថ្មម៉្យាងដែលមានសណ្ឋានដូចដើមឈើ។ អ្នកស្រុកស្ទឹងត្រែង និងក្រចេះបានពន្យល់ថាដើមគគីរនៅពេលវាចាស់ដល់កំរិតហើយកប់ក្នុងដីទៅវាក្លាយជាថ្ម(រូបលេខ១-២)។ ចំណែកនៅខេត្តរតនគិរី ក្នុងស្រុកលំផាត់ ក៏មានប្រភេទដើមឈើថ្មផងដែរ តែអ្នកស្រុកនៅតំបន់នោះ គេហៅថាឈ្វីកថ្ម(រូបលេខ៣) ដោយពួកគាត់ថាវាមានលក្ខណៈដូចគ្នានឹងដើមឈ្វីក និងមានពណ៌ខ្មៅ ។ រីឯនៅខេត្តព្រះវិហារ ពាក្យមួយទៀតក៏អាចមានទំនាក់ទំនងនឹងរឿងនេះដែរ នៅតំបន់ភ្នំត្បែងអ្នកស្រុកគេហៅថាធ្យូងកាល់ (ធ្យូងកប្ប?) សំដៅលើថ្មពណ៌ក្រម៉ៅ ដែលមានទ្រង់ទ្រាយដូចដើមឈើដែរ ដែលពួកគាត់និយាយថាវាជាធ្យូងដែលមានអាយុកាលជាយូរមកហើយ(រូបលេខ៤)។ **តើដើមឈើអាចក្លាយទៅជាថ្មបានដែរ ឬទេ?**

ដើមឈើពិតជាអាចក្លាយទៅជាថ្ម ដែលគេហៅថាផូស៊ីលឈើ ឬ Petrified Wood ។ អ្វីទៅជាផូស៊ីលឈើ? ផូស៊ីលឈើ Petrified Wood មានន័យថាឈើក្លាយជាថ្ម[១]។ វាកើតឡើងនៅពេលរុក្ខជាតិត្រូវបានកប់ដោយដីល្បាប់ និងការពារពីការពុកផុយដោយសារតែអុកស៊ីសែន និងសារធាតុសរីរាង្គនានា។ បន្ទាប់មកទឹកក្រោមដីដែលសំបូរទៅដោយសារធាតុរំលាយឆ្លងកាត់ដីល្បាប់ដោយជំនួសវត្ថុធាតុដើមរុក្ខជាតិដើមជាមួយស៊ីលីកា, កាស៊ីត ឬសារធាតុខនិចផ្សេងៗ ពេលខ្លះក៏មានឥទ្ធិពលពីភ្នំភ្លើង។ លទ្ធផល គឺជាផូស៊ីលនៃវត្ថុធាតុដើមឈើដែលជារឿយៗបង្ហាញនូវព័ត៌មានលម្អិត ដែលបានរក្សាទុកសំបកឈើ និង

[១] www.wikipedia.org

អត្ថបទដោយ៖ លោក លឹម វណ្ណច័ន្ទ

រចនាសម្ព័ន្ធកោសិកា។ គំរូខ្លះនៃឈើដែលបានការពារ គឺជាការអភិរក្សដ៏ត្រឹមត្រូវដែលមនុស្សមិនដឹងថាពួកគេជាផូស៊ីលរហូតដល់ពួកគេរើសវាហើយមានការភ្ញាក់ផ្អើលចំពោះទម្ងន់របស់ពួកគេ។ គំរូទាំងនេះជាមួយនឹងការអភិរក្សយ៉ាងល្អឥតខ្ចោះ គឺមិនធម្មតាទេ។ ទោះយ៉ាងណាក៏ដោយ សំណាកដែលបង្ហាញពីរចនាសម្ព័ន្ធឈើដែលអាចស្គាល់បានច្បាស់។ ដើមឈើចំណាយពេលជាច្រើនលានឆ្នាំ ដើម្បីប្រែកំណើតទៅជាថ្ម។

ឆ្នាំ២០១៩ និង២០២០ក្រុមការងារសិក្សាស្រាវជ្រាវផូស៊ីល នៃនាយកដ្ឋានតំបន់បេតិកភណ្ឌ អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន នៃក្រសួងបរិស្ថាន ដឹកនាំដោយលោក លឹម វណ្ណច័ន្ទ បានសិក្សា និងកំណាយស្រាវជ្រាវទីតាំងដើមឈើថ្ម ដែលស្ថិតនៅភូមិសាស្ត្រដែនជម្រកសត្វព្រៃលំផាត់ ស្រុកលំផាត់ ខេត្តរតនគិរី (រូបលេខ៥-៦-៧)។ ក្រុមការងារបានកំណាយក្នុងទំហំដី៤ម៉ែត្រគុណ និង២០ម៉ែត្រ ជម្រៅរហូត២ម៉ែត្រ ជាលទ្ធផល ៖

១. ដើមឈើថ្មមួយដើមធំ មានមុខកាត់ ៩០ស.ម គល់១៣៥ស.ម ឫស១៨០ស.ម បណ្ដោយ១៧ម៉ែត្រ ខាងចុងស្ថិតនៅទិសខាងជើងឆៀងខាងលិច និងផ្នែកគល់នៅទិសខាងត្បូងឆៀងខាងកើត។ ផ្នែកខាងចុងបានបាក់បែកជាបំណែកតូចៗ នៅផ្នែកឫសនៃដើមឈើទី១នេះ យើងបានរកឃើញបំណែកស្នឹកដែកកកនៅក្នុងថ្មនៃឫសឈើនេះ ជួបបំណែកនៃសំបកឈើ(រូបលេខ៨)។ ដំបូងឡើងផូស៊ីលដើមឈើនេះលេចចេញប្រវែង៤ម៉ែត្រ និងកំពស់១០ស.មមកខាងលើដី។ ដើមឈើដែលយើងបានធ្វើកំណាយឃើញនេះ វាមានស្នាមរង្វង់ចញ្ចៀនកម្រាស់ក្រាស់ៗ ដូចរង្វង់ចិញ្ចៀននៃដើមស្រល់ដែលអាចយល់បានថាជាប្រភេទដែលមានការលូតលាស់លឿន(រូបលេខ៩)។

២. ដើមឈើទី២ ស្ថិតនៅខាងជើងដើមឈើទី១ក្នុងរណ្ដៅកំណាយដែលមានប្រវែង៤ម៉ែត្រ ដោយផ្នែកខ្លះកប់នៅក្នុងដីនៅឡើយ។ ក្នុងនោះយើងបានរកឃើញបំណែកស្នឹកឈើដែលកប់ក្នុងថ្មនៃគល់ឈើទី២នេះផងដែរកាលពីឆ្នាំ២០១៩(រូបលេខ១០)។

៣. បំណែកដើមឈើ៣ផ្សេងទៀត មែកឈើ ឫសឈើមួយចំនួនក៏បានរកឃើញក្នុងរណ្ដៅកំណាយផងដែរ។

តាមការសិក្សាពិនិត្យទៅលើសំណាកផូស៊ីលដើមឈើ ដែលយើងបានរកឃើញតាមរយៈនៃការធ្វើកំណាយ យើងអាចយល់បានជាបឋមថា ដើមឈើទាំងឡាយអាច

អត្ថបទដោយ៖ លោក លឹម វណ្ណច័ន្ទ

ក្លាយទៅជាថ្មបាន ដោយយើងដឹងជាទូទៅថា ឈើងាយនឹងពុកពុយណាស់ទោះបីជាកប់ក្នុងដី ឬមិនកប់ក្នុងដីក៏ដោយ តែប្រភេទឈើដែលយើងកំណាយឃើញនេះ ជាប្រភេទឈើដែលធន់នឹងបរិស្ថានក្រោមដីដោយវាមិនងាយនឹងពុកកុយ និងប្រែក្លាយទៅថ្មទៅវិញ។ ហើយបើយើងពិនិត្យមើលទៅលើសំណាកឈើមួយចំនួន ដែលប្រមូលមកពីការដ្ឋានកំណាយខេត្តស្ទឹងត្រែង និងខេត្តរតនគីរី គឺអាយុកាលមិនតិចជាងរយឆ្នាំ ឬពាន់ឆ្នាំនោះទេ នេះអាចឱ្យយើងសន្និដ្ឋានជាបឋមបានថា ជាប្រភេទផូស៊ីលឈើ។ តែយើងក៏ពុំទាន់ដឹងថាដើមឈើនោះជាប្រភេទដើមឈើអ្វីឱ្យប្រាកដនៅឡើយទេ? ម្យ៉ាងមានប្រភេទដើមឈើខុសៗគ្នាបានក្លាយជាផូស៊ីលឈើ (រូបលេខ១២-១៣-១៤-១៥) ដូចនេះយើងត្រូវការពេលវេលាសិក្សាបន្ថែម និងសម្ភារៈវិភាគ។ ហើយដើមឈើទាំងឡាយអាចក្លាយជាផូស៊ីលដើមឈើអាចកើតបាន គឺមានប្រមាណ១ភាគរយតែប៉ុណ្ណោះដែលអាចមានឱកាសអាចកើតទៅបាន។ ដូច្នេះយើងគួរមានការថែរក្សា សិក្សាស្រាវជ្រាវ អភិរក្ស និងអភិវឌ្ឍនាពេលអនាគត ហើយយើងក៏សង្ឃឹមថាថ្ងៃណាមួយយើងនឹងអាចរកឃើញប្រភេទនៃដើមឈើថ្មទាំងឡាយដែលមានវត្តមានក្នុងប្រទេសកម្ពុជា។



រូបលេខ២១



រូបលេខ២២



រូបលេខ២៣



រូបលេខ២៤

អត្ថបទដោយ៖ លោក លឹម វណ្ណចន្ទ

# អត្ថបទ៖ តើដើមឈើអាចក្លាយជាថ្មបានយ៉ាងដូចម្តេច?


រូបលេខ៥


រូបលេខ៦


រូបលេខ៧


រូបលេខ៨


រូបលេខ៩


រូបលេខ១០


រូបលេខ១១


រូបលេខ១២


រូបលេខ១៣

អត្ថបទដោយ៖ លោក លឹម វណ្ណចន្ទ



រូបលេខ១៤



រូបលេខ១៥



រូបលេខ១៦



រូបលេខ១៧



រូបលេខ១៨

អត្ថបទដោយ៖ លោក លឹម វណ្ណច័ន្ទ